ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តកណ្ដាល
គណៈកម្មាធិការលទ្ធកម្ម
លេខ ៖ ............សជណ.អល.កណ

# សេចក្ដីជូនដំណឹង

## ស្ដីពីការងារសាងសង់អគារចំនួន ០២គម្រោង ជូនសាលាខេត្ត

ខេត្តកណ្ដាល សូមជូនដំណឹងដល់បណ្ដាក្រុមហ៊ុនសំណង់ (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថាខេត្តកណ្ដាលនឹងដាក់ឲ្យដេញថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកទទួលការធ្វើការងារសាងសង់អគារចំនួន ០២គម្រោងជូនសាលាខេត្ត៖

1- ការងារសាងសង់អគារសាលាឃុំ អំពីឥដ្ឋប្រក់ក្បឿងថៃ ទំហំ 10m x 14.60m ចំនួន ០៧ឃុំ (1- ឃុំកោះខ្សាច់ទន្លា ស្រុកស្អាង, 2- ឃុំបាគូ ស្រុកកណ្ដាលស្ទឹង, 3- ឃុំពញាឮ ស្រុកពញាឮ, 4-ឃុំកំពង់ភ្នំ ស្រុកលើកដែក, 5-ឃុំ ពាមរាំង ស្រុកលើកដែក, 6- ឃុំដំណាក់អំពិល ស្រុកអង្គស្នួល, 7- ឃុំបែកចាន ស្រុកអង្គស្នួល)

2- ការងារសាងសង់អគារមណ្ឌលសុខភាពកំពង់ភ្នំ អំពីបេតុងដែក ជញ្ជាំងរៀបឥដ្ឋ ដំបូលប្រក់ក្បឿងស៊ីផេក ទំហំ 16m x 9m ស្ថិតក្នុងភូមិក្បាលជ្រោយ ឃុំកំពង់ភ្នំ ស្រុកលើកដែក ។

ខេត្តកណ្ដាលបានរៀបចំឯកសារសម្រាប់ក្រុមហ៊ុនបំពេញ ដើម្បីចូលរួមដេញថ្លៃ និង មានដាក់លក់នៅអង្គភាពលទ្ធកម្មខេត្តកណ្ដាលមានអាសយដ្ឋានស្ថិតក្នុងសាលាខេត្តកណ្ដាលចាប់ពីថ្ងៃទី.១៧...ខែ.កក្កដា... ឆ្នាំ២០១៦ តទៅនៅរៀងរាល់ម៉ោងធ្វើការ ។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្មរដ្ឋបាលខេត្តកណ្ដាល យ៉ាងយូរបំផុតត្រឹមថ្ងៃទី .១៦..... ខែ.សីហា.....ឆ្នាំ២០១៦ វេលាម៉ោង .០៩.......និង.០០.......នាទី។

ការបើកឯកសារដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្មរដ្ឋបាលខេត្តកណ្ដាល តាមអាសយដ្ឋានខាងលើ វេលាម៉ោង.០៩.....និង.៣០......នាទី ថ្ងៃទី .១៦..... ខែ .សីហា... ឆ្នាំ២០១៦ ។

ក្រុមហ៊ុនដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់ឯកសារដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុនដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មរដ្ឋបាលខេត្តកណ្ដាលដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

នៅខេត្តកណ្ដាល, ថ្ងៃទី ១៥.... ខែ កក្កដា... ឆ្នាំ២០១៦
អភិបាល នៃគណៈអភិបាលខេត្ត
និងជាប្រធានគណៈកម្មាធិការលទ្ធកម្ម

ម៉ៅ ភិរុណ

ចម្លងជូន ÷
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
(អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារ-កាលប្បវត្តិ

3